Kingdom of Cambodia
Nation Religion King

*CTF - Translation*

Phnom Penh Municipality Administration
No. 019/21 សណន

ADDITIONAL INSTRUCTION
ON
Restricting the implementation of administrative measures for work, occupation or business activities and private gathering or meeting in Phnom Penh Geography

In the context of the spread of Covid-19, the **"20 November Community Event"** and after the Royal Government of Cambodia issued the Decision on the end of Lock down of Phnom Penh geography and Takhmao city of Kandal province, **Phnom Penh municipality administration** has always been paid high attention in implementing 3 measures, namely administrative, health and social protection measures, and gradually besides geographies defined as **" Dark Yellow Zone"**, some measures have been loosen up based upon necessary needs, business situation and the evolution of Covid-19.

As a remark, recently, while the administrative measures had been loosen up, owner of private companies, owner of financial institutions, factories- enterprise, owner of restaurants- canteen, businesses, construction sites, mart, store, management of State/ private market, civil servants, contracting personnels, administrative staffs, employees, workers, vendors, and some citizens seem to be neglect, forget to self-protect and failed to give attention in implementing or failed to implement the imposed measures, which is a risk causing severe outbreak, which may cause some geography becoming **" Yellow Zone", "Dark Yellow Zone" and "Red Zone"** over again.

Having seen the necessity to combat and prevent the spread of Covid-19, Phnom Penh municipality administration would like to remind and impose additional instruction, aiming to restrict the implementation of administrative measures for work, occupation or business activities and private gathering or meeting which are exempted, and not located in the **"Dark Yellow Zone"** in Phnom Penh geography as below:

1. Owner of private companies, owner of financial institutions, owner of factories- enterprise, owner of restaurants- canteen, businesses, construction sites, mart, store, management of State/ private market, civil servants, contracting personnels, administrative staffs, employees, workers, vendors, and all citizens residing, working or doing business and traveling across Phnom Penh geography, must be obliged to wear mask and maintain safety distance, in accordance with Prakas no. 81 ស.នក.ប្រក dated March, 2021 of Health Ministry on the

obligation to wear mask and maintain safety distance during the Covid-19 community outbreak.

2. Owner of private companies, owner of financial institutions, owner of factories- enterprise, owner of restaurants- canteen, businesses, construction sites, mart, store, management of State/ private market must arrange safety entrance- exit, limit entrance-exit, and limit guest entry capacity in a certain number appropriate with size of business premises to ensure physical-social distance, and ensure to have enough ventilation, avoiding crowded circulation or people gathering which is risk of Covid-19 spread and to maintain 1,5 meter safety distance in each business location.
3. Encourage owner of private companies, owner of financial institutions, owner of factories-enterprise, owner of restaurants- canteen, businesses, construction sites, mart, store, management of State/ private market, civil servants, contracting personnels, administrative staffs, employees, workers and all vendors to bring foods from home to eat while on duty at work place or while doing business, **but it's absolutely forbidden to gather to have meal or any gathering which failed to implement 1,5 meter safety measure, in whatever circumstance.**
4. Encourage owner of private companies, owner of financial institutions, owner of factories-enterprise, owner of restaurants- canteen, businesses, construction sites, mart, store, management of State/ private market to arrange staff canteen and pausing place for administrative staffs and workers/ employees, following health measures and must regularly clean workplace, business location or any site, to ensure safety and business sustainability in accordance with the "New normalization in the context to combat Covid-19 epidemic.
5. State market's management must continue to pay attention to adhere to the essence of the Decision no. 114/21 សិសិរ dated May 20th, 2021, of Phnom Penh municipality administration concerning the reopening of all State's market in Phnom Penh geography.
6. Encourage the citizens to stay home and avoid unnecessary travel. In case of necessary gathering, or travel, must be obliged to wear mask and maintain safety measures and abide by the Instruction of Health ministry, to prevent the Covid-19 spread.
7. Work, occupation or business activity at high risk of Covid-19 widespread namely, schools, including State/ private vocational training schools except school providing online class, c all kinds of entertaining clubs business, i.e., Karaoke, KTV, night club, beer garden, discotheque, casinos, resorts, museums and leisure park, massage and spa business, cinema, art performing hall, sport club, and gym etc. **shall continue to suspend operation till further notice**.
8. All work, occupation or business activities and private meeting or gathering must strictly implement health safety measures, keep good hygiene to disinfect, temperature screening, QR Code scanning and must follow Instruction of ministry of Health, competent ministries-institutions and local authorities.

Kingdom of Cambodia
Nation Religion King

9. All civil servants, contracting personnels, administrative staffs, employees, workers, vendors and all citizens must fully adhere to the "**3 Dos and 3 Don'ts measures**" of **Samdech Akka Moha Sena Padei Techo HUN Sen, Prime minister of Cambodia.**
10. The 14 Khan administrations and competent units/ department attached to Phnom Penh municipality administration must inspect all work, occupation or business activities which are exempted and work, occupation or business activities which shall continue to suspend as indicated in **Point 7 above** and all individual meeting, gathering in each location, in order to ensure accurate implementation of the essence of this Instruction. Any owner of private companies, owner of financial institutions, owner of factories- enterprise, owner of restaurants-canteen, businesses, construction sites, mart, store, management of State/ private market or any individual failed to collaborate with or implement this Instruction, must be subject to **administrative and legal measures including public announcement of the offenders,** accordingly with the Law on preventive measures against the spread of Covid-19 and other deadly infectious diseases and other relevant regulations in force, without any exception.

Having received this Instruction, Director of Phnom Penh Administration, Phnom Penh Police Commissioner, Commander of the Royal Gendarmerie of Phnom Penh, Governor of the Board of Governor of the 14 Khan, head of department, head of expert department, units attached to Phnom Penh administration, owner of private companies, owner of financial institutions, owner of factories- enterprise, owner of restaurants- canteen, businesses, construction sites, mart, store, management of State/ private market civil servants, contracting personnels, administrative staffs, employees, workers, vendors and all citizens must participate to implement this Instruction effectively with high responsibility spirit, from this signing date onward.

Phnom Penh, June 11th, 2021
**Governor of the Board of Governor of Phnom Penh**
*Signed and sealed*

KHUONG Sreng

***Receiving places:***

- *Ministers' council*
- *Interior Ministry*
- *Ministry of Economy and Finance*
- *Ministry of Health*
- *All ministries-institutions*
- *Phnom Penh Advisory Council*

***"For information"***

- *Phnom Penh Police Commissioner*
- *the Royal Gendarmerie of Phnom Penh*

Kingdom of Cambodia
Nation Religion King

- *the 14 Khan administration*
- *relevant Department-units attached to PP administration*

  ***"For officialize"***
- *all media*

  ***"For promoting"***
- *Document-chronology*

*Prepared by*

***Mrs. SUN Rasey,***
***Legal &compliance Manager, Thalias Co., Ltd***

***Disclaimer:*** *This document is a translation provided by* ***CTF*** *for information purposes only and shall not be regarded as an official translation. This translation has been prepared solely on the basis of information obtained from publicly available sources. While care has been taken to ensure the authenticity of those sources,* ***CTF*** *disclaims all responsibility and shall not be liable in any way (directly or indirectly) for the accuracy, completeness, or veracity of the information used in this document, or for any reliance upon this report by any party.*

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋបាលរាជធានីភ្នំពេញ**
លេខ : ០១៩/២១ សណន

# សេចក្តីណែនាំបន្ថែម
## ស្តីពី
## ការរឹតបន្តឹងការអនុវត្តវិធានការរដ្ឋបាល ចំពោះសកម្មភាពការងារ មុខរបរ ឬ អាជីវកម្ម និង ការជួបជុំ ឬ ការប្រមូលផ្តុំមនុស្សជាលក្ខណៈឯកជន នៅក្នុងភូមិសាស្ត្ររាជធានីភ្នំពេញ

ស្ថិតក្នុងបរិការណ៍នៃការឆ្លងរាលដាលជំងឺកូវីដ-១៩ ក្នុង **"ព្រឹត្តិការណ៍សហគមន៍ ២០ កុម្ភៈ ២០២១"** និង ក្រោយពេលដែលរាជរដ្ឋាភិបាលបានដាក់ចេញនូវសេចក្តីសម្រេច ស្តីពីការបិទបញ្ចប់ការបិទខ្ទប់ភូមិសាស្ត្ររាជធានីភ្នំពេញ និងក្រុងតាខ្មៅ នៃខេត្តកណ្តាល **រដ្ឋបាលរាជធានីភ្នំពេញ** បានបន្តយកចិត្តទុកដាក់អនុវត្តនូវវិធានការចំនួន **៣** គឺ វិធានការរដ្ឋបាល វិធានការសុខាភិបាល និងវិធានការគាំពារសង្គម ហើយជាបណ្តើរៗក្រៅអំពីភូមិសាស្ត្រដែលត្រូវបានកំណត់ជា **"តំបន់លឿងទុំ"** វិធានការមួយចំនួនត្រូវបានបន្ធូរបន្ថយ ផ្អែកតាមតម្រូវការចាំបាច់ ស្ថានភាពអាជីវកម្ម និងការវិវឌ្ឍនៃជំងឺកូវីដ-១៩ ជាក់ស្តែង។

ជាការកត់សម្គាល់ ក្នុងរយៈពេលចុងក្រោយនេះ ស្របពេលដែលវិធានការត្រូវបានបន្ធូរបន្ថយ ម្ចាស់ក្រុមហ៊ុនឯកជន ម្ចាស់គ្រឹះស្ថានហិរញ្ញវត្ថុ ម្ចាស់រោងចក្រ-សហគ្រាស ម្ចាស់ភោជនីយដ្ឋាន-អាហារដ្ឋាន ម្ចាស់អាជីវកម្មដ្ឋាន ម្ចាស់ការដ្ឋាន ម្ចាស់ផ្សារម៉ាត គណៈគ្រប់គ្រងផ្សាររដ្ឋ-ផ្សារឯកជន មន្ត្រីរាជការ បុគ្គលិកជាប់កិច្ចសន្យា បុគ្គលិករដ្ឋបាល កម្មករ-និយោជិត អាជីវករ និងបងប្អូនប្រជាពលរដ្ឋមួយចំនួន ហាក់មានការធ្វេសប្រហែស ភ្លេចការការពារខ្លួន និងមិនបានយកចិត្តទុកដាក់អនុវត្ត ឬ អនុវត្តមិនបានត្រឹមត្រូវនូវវិធានការកំណត់ **ដែលនេះ** គឺជាហានិភ័យអាចបណ្តាលឱ្យមានការឆ្លងរាលដាលធ្ងន់ធ្ងរក្នុងសហគមន៍ ហើយអាចនាំឱ្យភូមិសាស្ត្រមួយចំនួន ត្រូវប្រែក្លាយទៅជា **"តំបន់លឿង" "តំបន់លឿងទុំ"** និង **"តំបន់ក្រហម"** ជាថ្មីម្តងទៀត។

ចំពោះមុខ ដោយពិនិត្យឃើញពីភាពចាំបាច់ដើម្បីប្រយុទ្ធនិងទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ **រដ្ឋបាលរាជធានីភ្នំពេញ** សូមធ្វើការក្រើនរំលឹក និងដាក់ចេញនូវសេចក្តីណែនាំបន្ថែម សំដៅរឹតបន្តឹងការអនុវត្តវិធានការរដ្ឋបាល ចំពោះសកម្មភាពការងារ មុខរបរ ឬ អាជីវកម្ម និងការជួបជុំ ឬ ការប្រមូលផ្តុំមនុស្សជាលក្ខណៈឯកជន ដែលត្រូវបានលើកលែង និងមិនស្ថិតក្នុង **"តំបន់លឿងទុំ"** នៅរាជធានីភ្នំពេញ ដូចខាងក្រោម៖

១. ម្ចាស់ក្រុមហ៊ុនឯកជន ម្ចាស់គ្រឹះស្ថានហិរញ្ញវត្ថុ ម្ចាស់រោងចក្រ-សហគ្រាស ម្ចាស់ភោជនីយដ្ឋាន-អាហារដ្ឋាន ម្ចាស់អាជីវកម្មដ្ឋាន ម្ចាស់ការដ្ឋាន ម្ចាស់ផ្សារម៉ាត គណៈគ្រប់គ្រងផ្សាររដ្ឋ-ផ្សារឯកជន មន្ត្រីរាជការ បុគ្គលិកជាប់កិច្ចសន្យា បុគ្គលិករដ្ឋបាល កម្មករ-និយោជិត អាជីវករ និងបងប្អូនប្រជាពលរដ្ឋទាំងអស់ ដែលកំពុងស្នាក់នៅ បំពេញការងារ ប្រកបអាជីវកម្ម និងធ្វើដំណើរឆ្លងកាត់ភូមិសាស្ត្ររាជធានីភ្នំពេញ ត្រូវអនុវត្តឱ្យបានខ្ជាប់ខ្ជួននូវកាតព្វកិច្ចពាក់ម៉ាស និងកាតព្វកិច្ចរក្សាគម្លាតសុវត្ថិភាព ស្របតាមប្រកាសលេខ **៨១ ស.នក.ប្រក** ចុះថ្ងៃទី២២ ខែមីនា ឆ្នាំ២០២១ របស់ក្រសួងសុខាភិបាល ស្តីពីកាតព្វកិច្ចពាក់ម៉ាស និងកាតព្វកិច្ចរក្សាគម្លាតសុវត្ថិភាព ក្នុងអំឡុងពេលនៃការឆ្លងរាលដាលជំងឺកូវីដ-១៩ ក្នុងសហគមន៍។



៦៩មហាវិថីព្រះមុនីវង្ស រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ : (៨៥៥)២៣-៧២២ ៧៣៩ / ទូរសារ : (៨៥៥)២៣-៧២៥ ៦២៦ / ២៣-៧២២ ០៥៤
www.phnompenh.gov.kh; Email : info@phnompenh.gov.kh

២. ម្ចាស់ក្រុមហ៊ុនឯកជន ម្ចាស់គ្រឹះស្ថានហិរញ្ញវត្ថុ ម្ចាស់រោងចក្រ-សហគ្រាស ម្ចាស់ភោជនីយដ្ឋាន-អាហារដ្ឋាន ម្ចាស់អាជីវកម្មដ្ឋាន ម្ចាស់ការដ្ឋាន ម្ចាស់ផ្សារម៉ាត និងគណៈគ្រប់គ្រងផ្សាររដ្ឋ-ផ្សារឯកជន ត្រូវរៀបចំច្រកសុវត្ថិភាព កំណត់ច្រកចេញ-ចូល និងកំណត់ចំនួនអតិថិជនចេញ-ចូល ក្នុងបរិមាណសមរម្យសមាមាត្រទៅនឹងទំហំទីតាំង ដើម្បីរក្សាឱ្យបានជាដាច់ខាតនូវគម្លាតសុវត្ថិភាពបុគ្គល-សង្គម និងដើម្បីធានាឱ្យមានខ្យល់ចេញ-ចូលគ្រប់គ្រាន់ ដោយត្រូវចៀសវាងការប្រជ្រៀតគ្នា ឬ ប្រមូលផ្តុំមនុស្សច្រើន ដែលជាហានិភ័យនៃការចម្លងវីរុសកូវីដ-១៩ និងដើម្បីរក្សាគម្លាតសុវត្ថិភាព **១,៥ ម៉ែត្រ** ជាចាំបាច់ក្នុងបរិវេណទីតាំងនីមួយៗ។

៣. លើកទឹកចិត្តដល់ម្ចាស់ក្រុមហ៊ុនឯកជន ម្ចាស់គ្រឹះស្ថានហិរញ្ញវត្ថុ ម្ចាស់រោងចក្រ-សហគ្រាស ម្ចាស់ភោជនីយដ្ឋាន-អាហារដ្ឋាន ម្ចាស់អាជីវកម្មដ្ឋាន ម្ចាស់ការដ្ឋាន ម្ចាស់ផ្សារម៉ាត គណៈគ្រប់គ្រងផ្សាររដ្ឋ-ផ្សារឯកជន មន្ត្រីរាជការ បុគ្គលិកជាប់កិច្ចសន្យា បុគ្គលិករដ្ឋបាល កម្មករ-និយោជិត និងអាជីវករទាំងអស់ ឱ្យវេចខ្ចប់អាហារមកពីគេហដ្ឋានរៀងៗខ្លួន សម្រាប់ទទួលទាននៅក្នុងអំឡុងពេលបំពេញការងារ ឬ ប្រកបអាជីវកម្ម **ប៉ុន្តែ ហាមដាច់ខាតការជួបជុំប្រមូលផ្តុំគ្នាទទួលទានអាហារ ឬ ការជួបជុំដែលមិនរក្សាបាននូវគម្លាតសុវត្ថិភាព ១,៥ ម៉ែត្រ ទោះក្រោមរូបភាពណាក៏ដោយ។**

៤. លើកទឹកចិត្តដល់ម្ចាស់ក្រុមហ៊ុនឯកជន ម្ចាស់គ្រឹះស្ថានហិរញ្ញវត្ថុ ម្ចាស់រោងចក្រ-សហគ្រាស ម្ចាស់ភោជនីយដ្ឋាន-អាហារដ្ឋាន ម្ចាស់អាជីវកម្មដ្ឋាន ម្ចាស់ការដ្ឋាន ម្ចាស់ផ្សារម៉ាត និងគណៈគ្រប់គ្រងផ្សារឯកជន គួររៀបចំកន្លែងសម្រាក និងកន្លែងទទួលទានអាហារ សម្រាប់បុគ្គលិករដ្ឋបាល និងកម្មករ-និយោជិត របស់ខ្លួន ដោយគោរពទៅតាមវិធានសុខាភិបាល និងត្រូវសម្អាតអនាម័យក្នុងទីកន្លែងបំពេញការងារ ទីតាំងអាជីវកម្ម ឬ ការដ្ឋាននីមួយៗជាប់ជាប្រចាំ ដើម្បីធានាសុវត្ថិភាព និងរក្សាបាននូវនិរន្តរភាពអាជីវកម្ម ស្របតាមបែបផែន **"សភាពធម្មតាបែបគន្លងថ្មី ក្នុងបរិបទប្រយុទ្ធនឹងជំងឺកូវីដ-១៩"** ។

៥. ចំពោះគណៈគ្រប់គ្រងផ្សាររដ្ឋ ត្រូវបន្តយកចិត្តទុកដាក់អនុវត្តឱ្យបានត្រឹមត្រូវតាមខ្លឹមសារនៃសេចក្តីសម្រេចលេខ ១១៤/២១ សសរ ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២១ របស់រដ្ឋបាលរាជធានីភ្នំពេញ ស្តីពីការបើកដំណើរការឡើងវិញចំពោះផ្សាររដ្ឋទាំងអស់ ក្នុងមូលដ្ឋានរាជធានីភ្នំពេញ។

៦. លើកទឹកចិត្តដល់បងប្អូនប្រជាពលរដ្ឋសូមបន្តស្នាក់នៅក្នុងលំនៅឋានរៀងៗខ្លួន និងចៀសវាងការធ្វើដំណើរដែលមិនចាំបាច់។ ក្នុងករណីមានតម្រូវការខានមិនបានក្នុងការជួបជុំបងប្អូនញាតិមិត្ត ឬ ត្រូវធ្វើដំណើរចាំបាច់ ត្រូវប្រកាន់ខ្ជាប់កាតព្វកិច្ចពាក់ម៉ាស កាតព្វកិច្ចរក្សាគម្លាតសុវត្ថិភាព និងអនុវត្តតាមការណែនាំរបស់ក្រសួងសុខាភិបាល ដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ ។

៧. សកម្មភាពការងារ មុខរបរ ឬ អាជីវកម្មដែលមានហានិភ័យខ្ពស់នៃការឆ្លងរាលដាលជំងឺកូវីដ-១៩ ដូចជាសាលារៀន រួមទាំងសាលាបណ្តុះបណ្តាលវិជ្ជាជីវៈទាំងរដ្ឋ និងឯកជន លើកលែងតែសាលារៀនដែលធ្វើការបណ្តុះបណ្តាលតាមប្រព័ន្ធអនឡាញ, អាជីវកម្មក្លឹបកម្សាន្តគ្រប់ប្រភេទ ជាអាទិ៍ ខារ៉ាអូខេ រង្គសាល ឌីស្កូតែក បៀហ្គាឌិន និងកាស៊ីណូ, រមណីយដ្ឋាន សារមន្ទីរ និងសួនកម្សាន្តនានា, អាជីវកម្មម៉ាស្សា, រោងភាពយន្ត, រោងសម្តែងសិល្បៈ, ក្លឹបហាត់ប្រាណ និងមជ្ឈមណ្ឌលកីឡា ជាដើម **ត្រូវបន្តផ្អាកដំណើរការជាបណ្តោះអាសន្ន រហូតដល់មានការសម្រេចជាថ្មី**។

៨. គ្រប់សកម្មភាពការងារ មុខរបរ ឬ អាជីវកម្ម និងការជួបជុំ ឬ ការប្រមូលផ្តុំមនុស្សជាលក្ខណៈឯកជន ត្រូវអនុវត្តវិធានការសុវត្ថិភាពផ្នែកសុខាភិបាលឱ្យបានម៉ឺងម៉ាត់ ជាអាទិ៍ កាតព្វកិច្ចពាក់ម៉ាស កាតព្វកិច្ចរក្សាគម្លាតសុវត្ថិភាព ការធ្វើអនាម័យដើម្បីសម្លាប់មេរោគ ការវាស់កម្តៅ ការស្កេន QR Code និងត្រូវអនុវត្តតាមការណែនាំរបស់ក្រសួងសុខាភិបាល ក្រសួង-ស្ថាប័នជំនាញ និងអាជ្ញាធរមូលដ្ឋាន។



៦៩មហាវិថីព្រះមុនីវង្ស រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ : (៨៥៥)២៣-៧២២ ៧៣៩ / ទូរសារ : (៨៥៥)២៣-៧២៥ ៦២៦ / ២៣-៧២២ ០៥៤
www.phnompenh.gov.kh; Email : info@phnompenh.gov.kh

៩. មន្ត្រីរាជការ បុគ្គលិកជាប់កិច្ចសន្យា បុគ្គលិករដ្ឋបាល កម្មករ-និយោជិត អាជីវករ និងបងប្អូនប្រជាពលរដ្ឋ ត្រូវប្រកាន់ខ្ជាប់ជានិច្ចនូវវិធានការ "**៣ ការពារ និង ៣ កុំ**" របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា។

១០. រដ្ឋបាលខណ្ឌទាំង១៤ និងមន្ទីរ-អង្គភាពជំនាញជុំវិញរដ្ឋបាលរាជធានីភ្នំពេញ ត្រូវចុះត្រួតពិនិត្យគ្រប់ពេលវេលានូវសកម្មភាពការងារ មុខរបរ ឬ អាជីវកម្មដែលត្រូវបានលើកលែង និងសកម្មភាពការងារ មុខរបរ ឬ អាជីវកម្មដែលត្រូវបន្តផ្អាកដំណើរការក្នុង**ចំណុចទី៧** ខាងលើ ព្រមទាំងការជួបជុំ ឬ ការប្រមូលផ្តុំមនុស្សជាលក្ខណៈឯកជនក្នុងមូលដ្ឋាននីមួយៗ ដើម្បីធានាការអនុវត្តឱ្យបានត្រឹមត្រូវតាមខ្លឹមសារនៃសេចក្តីណែនាំនេះ។ ក្នុងករណីរកឃើញថា ម្ចាស់ក្រុមហ៊ុនឯកជន ម្ចាស់គ្រឹះស្ថានហិរញ្ញវត្ថុ ម្ចាស់រោងចក្រ-សហគ្រាស ម្ចាស់ភោជនីយដ្ឋាន-អាហារដ្ឋាន ម្ចាស់អាជីវកម្មដ្ឋាន ម្ចាស់ការដ្ឋាន ម្ចាស់ផ្សារម៉ាត គណៈគ្រប់គ្រងផ្សាររដ្ឋ-ផ្សារឯកជន ឬ បុគ្គលណាមួយ មិនព្រមសហការ ឬ មិនអនុវត្តតាមសេចក្តីណែនាំនេះ **ត្រូវចាត់វិធានការរដ្ឋបាល និងវិធានការច្បាប់ រួមទាំងការផ្សព្វផ្សាយជាសាធារណៈចំពោះបុគ្គលល្មើស** ស្របតាមច្បាប់ស្តីពីវិធានការទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវ និងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត និង លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន ដោយគ្មានការលើកលែងឡើយ។

ទទួលបានសេចក្តីណែនាំនេះ នាយករដ្ឋបាលសាលារាជធានីភ្នំពេញ ស្នងការនគរបាលរាជធានីភ្នំពេញ មេបញ្ជាការកងរាជអាវុធហត្ថរាជធានីភ្នំពេញ អភិបាល នៃគណៈអភិបាលខណ្ឌទាំង១៤ ប្រធានមន្ទីរ-អង្គភាពជំនាញជុំវិញរដ្ឋបាលរាជធានីភ្នំពេញ ម្ចាស់ក្រុមហ៊ុនឯកជន ម្ចាស់គ្រឹះស្ថានហិរញ្ញវត្ថុ ម្ចាស់រោងចក្រ-សហគ្រាស ម្ចាស់ភោជនីយដ្ឋាន-អាហារដ្ឋាន ម្ចាស់អាជីវកម្មដ្ឋាន ម្ចាស់ការដ្ឋាន ម្ចាស់ផ្សារម៉ាត គណៈគ្រប់គ្រងផ្សាររដ្ឋ-ផ្សារឯកជន មន្ត្រីរាជការ បុគ្គលិកជាប់កិច្ចសន្យា បុគ្គលិករដ្ឋបាល កម្មករ-និយោជិត អាជីវករ បងប្អូនប្រជាពលរដ្ឋ និងគ្រប់ភាគីពាក់ព័ន្ធទាំងអស់ ត្រូវចូលរួមអនុវត្តតាមខ្លឹមសារនៃសេចក្តីណែនាំនេះ ឱ្យមានប្រសិទ្ធភាព និងប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់៕

ថ្ងៃសុក្រ ៤ កើត ខែបឋមាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០២១
**អភិបាល នៃគណៈអភិបាលរាជធានីភ្នំពេញ**

**ឃួង ស្រេង**

**កន្លែងទទួល៖**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងសុខាភិបាល
- គ្រប់ក្រសួង-ស្ថាប័ន
  *"ដើម្បីជូនជ្រាបជាព័ត៌មាន"*
- ស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ
- បញ្ជាការដ្ឋានកងរាជអាវុធហត្ថរាជធានីភ្នំពេញ
- រដ្ឋបាលខណ្ឌទាំង១៤
- គ្រប់មន្ទីរ-អង្គភាពជំនាញជុំវិញរដ្ឋបាលរាជធានីភ្នំពេញ
  *"ដើម្បីអនុវត្ត"*
- គ្រប់ប្រព័ន្ធឃោសនា
  *"ដើម្បីផ្សព្វផ្សាយ"*
- ឯកសារ-កាលប្បវត្តិ



៦៩មហាវិថីព្រះមុនីវង្ស រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ : (៨៥៥)២៣-៧២២ ៧៣៩ / ទូរសារ : (៨៥៥)២៣-៧២៥ ៦២៦ / ២៣-៧២២ ០៥៤
www.phnompenh.gov.kh; Email : info@phnompenh.gov.kh